**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៨៨ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន



៥

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (**ក.ជ.អ.ច.**)។

## ជំពូកទី២

## ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានក.ជ.អ.ច.

**មាត្រា២ .-**

អគ្គលេខាធិការដ្ឋាន**ក.ជ.អ.ច.** មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលនិងគាំទ្រដល់ការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- ដឹកនាំ សម្របសម្រួល និងអនុវត្តបំពេញនីតិវិធី ដើម្បីឱ្យអគ្គលេខាធិការដ្ឋាន**ក.ជ.អ.ច.** មានសម្បទាទទួលស្គាល់ដោយស្ថាប័នមូលនិធិអន្តរជាតិស្របច្បាប់
- សម្របសម្រួលនិងអនុវត្តការងារប្រចាំថ្ងៃតាមការណែនាំនិងសេចក្តីសម្រេចនានារបស់**ក.ជ.អ.ច.**
- លើកសំណើបង្កើតយន្តការចាំបាច់សម្រាប់កិច្ចការតាមវិស័យដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់**ក.ជ.អ.ច.** និងផ្តល់ការគាំទ្រដល់សកម្មភាពនានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការការងារជាប្រចាំរបស់យន្តការនានា
- សម្របសម្រួលនិងគាំទ្រដល់ការពង្រឹងកិច្ចសហប្រតិបត្តិការទាក់ទងនឹងការអភិវឌ្ឍដោយចីរភាពជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ
- រៀបចំកម្មវិធីនិងផែនការការងារជូន**ក.ជ.អ.ច.** ដើម្បីពិនិត្យនិងសម្រេច ព្រមទាំងតាមដានការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តការងារ
- ដឹកនាំនិងសម្របសម្រួលការងារសិក្សា ស្រាវជ្រាវ អប់រំ បណ្តុះបណ្តាល និងផ្លាស់ប្តូរបច្ចេកវិទ្យាពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- ពិនិត្យ សិក្សា និងវាយតម្លៃរាល់សំណើគម្រោងទាំងអស់ ដើម្បីស្នើសុំការសម្រេចពី**ក.ជ.អ.ច.**

- គ្រប់គ្រងទិន្នន័យ ស្ថិតិ និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាពនិងសកម្មភាពនានារបស់**ក.ជ.អ.ច.**
- ពិនិត្យ សិក្សា និងលើកយោបល់អំពីលទ្ធភាពនៃការចូលរួមក្នុងកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាពជូន**ក.ជ.អ.ច.**
- ចូលរួមកិច្ចប្រជុំនានានៅថ្នាក់ជាតិនិងថ្នាក់អន្តរជាតិលើបញ្ហាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- រៀបចំសេចក្ដីព្រាងឯកសារជំហរនិងយុទ្ធសាស្ត្រជូន**ក.ជ.អ.ច.** សម្រាប់ចូលរួមក្នុងកិច្ចចរចាអន្តរជាតិនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- សម្របសម្រួលរៀបចំរបាយការណ៍ជាតិ ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក
- គ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស ធនធានហិរញ្ញវត្ថុនិងថវិកា ទ្រព្យសម្បត្តិរដ្ឋ និងការងារអធិការកិច្ចនិងសវនកម្មផ្ទៃក្នុងរបស់**ក.ជ.អ.ច.**
- រៀបចំកិច្ចប្រជុំនានា ធ្វើកំណត់ហេតុនិងរបាយការណ៍របស់**ក.ជ.អ.ច.**
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូន**ក.ជ.អ.ច.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន**ក.ជ.អ.ច.**។

## ជំពូកទី៣
## ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក.ជ.អ.ច.

**មាត្រា៣ ._**

អគ្គលេខាធិការដ្ឋាន**ក.ជ.អ.ច.** ដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប និងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការតែងតាំង ការផ្លាស់ប្ដូរនិងការបញ្ចប់ភារកិច្ច អគ្គលេខាធិការនិងអគ្គលេខាធិការរងត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា៤ ._**

អគ្គលេខាធិការត្រូវធ្វើការបែងចែកភារកិច្ចនិងអាចធ្វើប្រតិភូកម្មអំណាចដល់អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន**ក.ជ.អ.ច.**។

**មាត្រា៥ ._**

អគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន**ក.ជ.អ.ច.** ត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះ**ក.ជ.អ.ច.**។

**មាត្រា៦ ._**

អគ្គលេខាធិការដ្ឋាន**ក.ជ.អ.ច.** មានរចនាសម្ព័ន្ធចំណុះកម្រិតការិយាល័យចំនួន៣(បី)។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះអគ្គលេខាធិការដ្ឋាន**ក.ជ.អ.ច.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



ថ

**មាត្រា៧ .-**

អគ្គលេខាធិការដ្ឋាន**ក.ជ.អ.ច.** អាចបង្កើតក្រុមការងារជំនាញដើម្បីជួយគាំទ្រដល់ដំណើរការនៃការអនុវត្តមុខងាររបស់ខ្លួន។

មុខងារនិងភារកិច្ចរបស់ក្រុមការងារជំនាញត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន**ក.ជ.អ.ច.**។

## ជំពូកទី៤

## ប្រភពធនធាន

**មាត្រា៨ .-**

អគ្គលេខាធិការដ្ឋាន**ក.ជ.អ.ច.** មានធនធានសម្រាប់អនុវត្តសកម្មភាពដោយថវិកាជាតិនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងបរិស្ថាន និងប្រភពធនធានស្របច្បាប់ផ្សេងទៀត។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ